សូមអាន

ព័ត៌មានសំខាន់អំពី Medicare Advantage Plan និង Cal MediConnect របស់លោកអ្នក

លោកអ្នកកំពុងទទួលបានសំបុត្រនេះ ដោយសារតែលោកអ្នកមានសិទ្ធិចូលរួមកម្មវិធី Cal MediConnect ហើយលោកអ្នកនៅក្នុងគម្រោង Medicare Advantage Plan សព្វថ្ងៃនេះ។ យើងចង់ឲ្យលោកអ្នកដឹងនូវរបៀបដែល Medicare និង Medi-Cal បច្ចុប្បន្នរបស់លោកអ្នកនឹងផ្លាស់ប្តូរ។

- លោកអ្នកនឹងនៅតែទទួលអត្ថប្រយោជន៍ Medicare និង Medi-Cal របស់លោកអ្នក។
- នឹងមិនមានចន្លោះនៅក្នុងការបង់ធានារ៉ាប់រងរបស់លោកអ្នកទេ។
- លោកអ្នកនឹងមានជម្រើសថ្មីៗ សំរាប់ការបង់ធានារ៉ាប់រង Medicare និង Medi-Cal របស់លោកអ្នក។

ជាមួយនឹងសំបុត្រនេះ និងសំបុត្រផ្សេងៗទៀត ដែលលោកអ្នកនឹងទទួលបានអំពី Cal MediConnect លោកអ្នកនឹងមានជម្រើសអំពីរបៀបដែលលោកអ្នកនឹងទទួលបានការថែទាំសុខភាពរបស់លោកអ្នក។ សូមអានព័ត៌មាន ដែលលោកអ្នកទទួលបានដោយប្រុងប្រយ័ត្ន។ សូមទូរស័ព្ទមកយើងខ្ញុំនៅលេខទូរស័ព្ទទាំងឡាយ នៅទំព័របន្ទាប់ បើលោកអ្នកមានសំណួរ ហើយយើងខ្ញុំអាចជួយលោកអ្នកបាន។

ចុះបើខ្ញុំមិនធ្វើអ្វីសោះ?

បើលោកអ្នកមិនធ្វើអ្វីសោះ លោកអ្នកនឹងត្រូវបានចុះឈ្មោះនៅក្នុងគម្រោង Cal MediConnect ដែលត្រូវបានផ្តល់ដោយក្រុមហ៊ុនដដែល ដែលជាគម្រោង Medicare បច្ចុប្បន្នរបស់លោកអ្នក។

តើជម្រើសរបស់ខ្ញុំដទៃទៀតមានអ្វីខ្លះ?

លោកអ្នកមានជម្រើសពីរផ្សេងៗទៀត សំរាប់របៀបទទួលអត្ថប្រយោជន៍ Medicare និង Medi-Cal របស់លោកអ្នក។

ជម្រើស A៖ ចុះឈ្មោះក្នុងគម្រោង Cal MediConnect មួយ។ គម្រោងថ្មីនឹងផ្តល់អត្ថប្រយោជន៍ Medicare និង Medi-Cal របស់លោកអ្នក។ លោកអ្នកនឹងចុះឈ្មោះដោយស្ម័យប្រវត្តិ នៅក្នុងគម្រោង Cal MediConnect ដែលត្រូវបានផ្តល់ដោយក្រុមហ៊ុនដដែល ដូចដែលគម្រោង Medicare បច្ចុប្បន្នរបស់លោកអ្នក ឬលោកអ្នកអាចជ្រើសរើសគម្រោង Cal MediConnect មួយផ្សេងទៀតក៏បាន។ លោកអ្នកគួរតែពិនិត្យជាមួយគម្រោង ឬកម្មវិធី California Health Insurance Counseling and Advocacy Program ដើម្បីដឹងថាតើអ្នកផ្តល់សេវារបស់លោកអ្នកនឹងនៅតែស្ថិតក្នុងបណ្តាញរបស់គម្រោង ឬមួយលោកអ្នកត្រូវការផ្លាស់ប្តូរអ្នកផ្តល់សេវា។

ជម្រើស B៖ ចុះឈ្មោះនៅក្នុងគម្រោង Medi-Cal៖ បើលោកអ្នកធ្វើការជ្រើសរើសនេះ លោកអ្នកនឹងទទួលអត្ថប្រយោជន៍ Medicare របស់លោកអ្នក តាមរយៈ Medicare ធម្មតា ហើយមិនតាមរយៈគម្រោងសុខភាព។

- លោកអ្នកនឹងទទួលបានអត្ថប្រយោជន៍ Medicare របស់លោកអ្នក តាមរយៈ Medicare ធម្មតា ហើយមិនតាមរយៈគម្រោងសុខភាព។ លោកអ្នកគួរតែចុះឈ្មោះផងដែរនៅក្នុងគម្រោងថ្នាំវេជ្ជបញ្ជា Medicare មួយ។ បើលោកអ្នកមិនធ្វើដូច្នេះទេ Medicare នឹងចុះឈ្មោះលោកអ្នកឲ្យចូលរួមក្នុងគម្រោងមួយ។

(ត្រឡប់)

- លោកអ្នកនឹងទទួលអត្ថប្រយោជន៍ Medi-Cal ពីគម្រោង Medi-Cal មួយផ្សេងទៀត។ នេះមានរួមទាំង In-Home Supportive Services (IHSS), Multipurpose Senior Services Program (MSSP), Community-Based Adult Services (CBAS) និងការថែទាំមន្ទីរថែទាំជរាពិការ បើលោកអ្នកមានសិទ្ធិទទួលសេវាកម្មទាំងនេះ។

នៅក្នុងសំបុត្រមួយទៀត ដែលលោកអ្នកបានទទួល ជាមួយព័ត៌មានបញ្ចូលនេះ ជម្រើស B នេះ ត្រូវបានបិទផ្លាកថា៖ ***"រក្សាទុក Medicare របស់ខ្ញុំដូចរបៀបដែលវាមានឥឡូវនេះ ហើយចុះឈ្មោះក្នុងគម្រោង Medi-Cal។"*** ដោយសារតែលោកអ្នកនៅក្នុង Medicare Advantage Plan លោកអ្នកមិនអាចរក្សាទុក Medicare របស់លោកអ្នកដូចរបៀបដែលវាមានឥឡូវនេះបានទេ បើលោកអ្នកជ្រើសរើសជម្រើស B។

សំបុត្រមួយដោយមានព័ត៌មានថែមទៀត អំពី Cal MediConnect និងជម្រើសនានារបស់លោកអ្នក មានរួមបញ្ចូលជាមួយព័ត៌មានបញ្ចូលនេះ។

តើខ្ញុំអាចទទួលបានព័ត៌មានថែមទៀត យ៉ាងដូចម្តេច?

បើលោកអ្នកចង់៖	**សូមទាក់ទង៖**
និយាយជាមួយទីប្រឹក្សាធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ អំពីការផ្លាស់ប្តូរទាំងនេះ និងជម្រើសនានារបស់លោកអ្នក។	California Health Insurance Counseling & Advocacy Program (HICAP) តាមលេខ 1-800-434-0222 ឬ TTY 711
ជ្រើសរើសគម្រោង Cal MediConnect មួយផ្សេងទៀត រក្សាទុក Medicare របស់លោកអ្នកដោយឡែក ហើយជ្រើសរើសគម្រោង Medi-Cal មួយ ទទួលសំបុត្រនេះជាភាសាផ្សេងទៀត អក្សរពុម្ពធំ សំឡេង ឬ Braille	សេវាកម្មបម្រើអតិថិជន Health Care Options ថ្ងៃចន្ទ–ថ្ងៃសុក្រ ម៉ោង 8:00 ព្រឹក – 5:00 ល្ងាច តាមលេខ 1-844-580-7272 ឬ TTY: 1-800-430-7077
មានតែបើលោកអ្នកជ្រើសរើសជម្រើស B ប៉ុណ្ណោះ ទើបលោកអ្នកអាច៖ ជ្រើសរើសគម្រោង Medicare មួយផ្សេងទៀត ជ្រើសរើសគម្រោងថ្នាំវេជ្ជបញ្ជា Medicare មួយផ្សេងទៀត	1-800-MEDICARE (1-800-633-4227)